ខ្មោចលង

សេរីការ

ខ្មោចលង

មេបនរបបភ្នំពេញ គំរាមដល់គណបក្សប្រឆាំងថា បើអន្តរជាតិ ដាក់គំនាបសេដ្ឋកិច្ចមកលើកម្ពុជា ខ្លួននឹងកម្ទេចបន្ថែមទៀតគណបក្សប្រឆាំង។ សួរថា តើកម្ទេចបែបណាតទៅទៀត បើសព្វថ្ងៃ អង្គការជាផ្លូវការ នៃគណបក្សប្រឆាំង នៅក្នុងស្រុកខ្មែរ ត្រូវមេបននេះ សម្លាប់បាត់រួចទៅហើយ ? ដូច្នេះការគំរាមនេះ វាហាក់បីដូចជា មេបននេះ កំពុងខ្មោចលងហើយខឹង ឬ ខ្លាចខ្មោច ស្រែកឡូងឡាងប្រាប់គេឯងថា ខ្លួនចង់ បន្តសម្លាប់ខ្មោចថែមទៀត បើខ្មោចនោះ វាចេះតែតាមមកលងខ្លួនរៀងរាល់រាត្រី។ ខ្មោចតាមលង វាអាចជារឿងពិតនៅក្នុងអារម្មណ៍ របស់មេបននេះ ព្រោះនៅក្នុងស្មារតី របស់ខ្លួន វាដឹងច្បាស់ថាខ្លួន ជាឃាតករនយោបាយ សម្លាប់គណបក្សប្រឆាំង និងសេរីភាព នៃប្រជាពលរដ្ឋដោយបំពានច្បាប់។ ការដឹងខ្លួនដូច្នេះ វានាំឱ្យខ្លួនភ័យខ្លាច ព្រលឹងខ្មោច ដែលវាតាមលងខ្លួនជានិច្ច។ ដូច្នេះ មេបននេះ ពុំអាចដេកស្ងប់បាននោះឡើយ, ល្គឹកណាតែខ្លួន ធ្វើបុណ្យ បួងសួងសុំឱ្យ ព្រលឹងលទ្ធិប្រជាធិបតេយ្យឈ្នះឈ្នះ មកការពារខ្លួន ទើបរកឃើញ ចិត្តស្ងប់បាន។ មិនមែនធ្វើស្តូប « ឈ្នះឈ្នះ » សំរាប់ដឹងគុណយួននោះឡើយ ព្រោះវាជាសំណង់ នៃការអាម៉ាស់ដល់ប្រជាជាតិខ្មែរ ដែលនាំឱ្យចិត្ត នៃមេបននោះ ស្ថិតនៅឋានខ្មោចជានិច្ច។

ឧប សៅ សង្ហា **យោបល់** **១៦ មករា ២០១៨**

ខ្មោចលង

ហេតុនេះឯង បានជាមនុស្សនោះ មានចិត្តជ្រមូសនឹងអំពើឃាតកម្មជានិច្ច។

ម្យ៉ាងមួយទៀត មេបននោះ គាត់ខ្លាចខ្មោច រហូតរត់រកព្រះស្វេតច្ឆ័ត្រ នៃព្រះមហាក្សត្រ សំរាប់យកមកបាំងការពារខ្មោច ព្រោះ គាត់ មានជំនឿថា ខ្លួនពាក់ងារជា « សម្តេចតេជោ » អាចមានឫទ្ធិពេញសិទ្ធិ អាចទៅជ្រកកោនក្រោមឆាយា នៃព្រះស្វេតច្ឆ័ត្រ ដូចព្រះរាជាបាន។ ទង្វើនេះ ក៏រិតតែបង្ហាញថា មនុស្សខ្លាំងនោះ តាមពិតជាមនុស្សកំសាកបំផុត មិនដែលហ៊ានទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួន។ សព្វថ្ងៃ គាត់ទុកយួន ជាអ្នកមានគុណលើគាត់, ប្រើព្រះមហាក្សត្រ ធ្វើជាខែល ការពារអំពើទុច្ចរិត របស់គាត់ និង យកចិនកុម្មុយនិស្តជាធានាគារ សំរាប់ខ្ចីលុយ សំរាប់យកមកចាយខ្ជះខ្ជាយ ដើម្បីពង្រឹងអំណាច នៃបនគាត់។ គំនិត នៃការការពារសន្តិភាពស្ថាពរ របស់គាត់ វាគ្រាន់តែជា អំពើប្រឆាំងនឹងប្រយោជន៍ជាតិតែប៉ុណ្ណោះ។ គំនិតល្អ សំរាប់ជាតិ គឺត្រូវ គេគោរពដោយមេត្រីភាព មិនមែន យកការគំរាមមកបង្ខំឱ្យគេជឿបាននោះឡើយ។ ដូច្នោះឯង បានជាខ្មោចនៅតែតាមលងគាត់ជានិច្ច ព្រោះព្រលឹងជាតិ ពុំអាចមានមេត្រីភាព ជាមួយមនុស្សបំផ្លាញជាតិបានទេ។ មេបននោះ ដែលតាំងខ្លួនជាមេទ័ព គួរចងចាំនូវបាវចៈនាយោធាថា : ការងារ សម្រាប់ច្បាប់ ; កិត្តិយស ជាផ្លូវ នៃការណែនាំ៕